





# សារអបអរសាទរ របស់ ឯកឧត្តម ខៀវ កាញារីទ្ធ

## រដ្ឋមន្ត្រីក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាស ខួបអនុស្សាវរីយ៍២០ឆ្នាំ នៃការប្រគល់ម៉ាកាវមកប្រទេសចិនវិញ

ឆ្លៀតក្នុងឱកាសខួបអនុស្សាវរីយ៍២០ឆ្នាំនៃការប្រគល់ម៉ាកាវមកប្រទេសចិនវិញ ខ្ញុំសូមតំណាងឲ្យក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា សូមចូលរួមអបអរសាទរយ៉ាងកក់ក្តៅ ជូនចំពោះខួបអនុស្សាវរីយ៍២០ឆ្នាំ នៃការបង្កើតតំបន់រដ្ឋបាលពិសេសម៉ាកាវ និងសមិទ្ធផលដ៏អស្ចារ្យដែលទទួលបានកន្លងមក។

ឆ្នាំនេះជាឆ្នាំនៃខួបអនុស្សាវរីយ៍៧០ឆ្នាំ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន និងខួបអនុស្សាវរីយ៍២០ឆ្នាំនៃការប្រគល់ម៉ាកាវមកប្រទេសចិនវិញផងដែរ។ នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ ម៉ាកាវត្រូវបានប្រគល់មកប្រទេសចិនវិញជាស្ថាពរ ហើយតំបន់រដ្ឋបាលពិសេសម៉ាកាវក៏ត្រូវបានបង្កើតឡើងជាស្ថាពរ ហើយក៏បានចាប់ផ្តើមដើរលើវិថីអភិវឌ្ឍន៍ស្វ័យគ្រប់គ្រងកម្រិតខ្ពស់នៃគោលនយោបាយ «ប្រទេសមួយប្រព័ន្ធពីរ» និងគោលនយោបាយ«ម៉ាកាវគ្រប់គ្រងដោយចិនម៉ាកាវ»។ ស្ថិតនៅក្រោមការដឹកនាំនៃគោលនយោបាយ បានធ្វើឲ្យវិស័យនានានៃសេដ្ឋកិច្ច និងសង្គមកិច្ចម៉ាកាវទទួលបានការអភិវឌ្ឍបានយ៉ាងឆាប់រហ័ស ក៏បានក្លាយជារូបរាងដ៏អស្ចារ្យថ្មីមួយ។ GDP សម្រាប់មនុស្សម្នាក់ក្នុងម៉ាកាវបានកើនពី១៥០០០ដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៩ មក៨៦០០០ដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០១៨ក៏បានជាប់ចំណាត់ថ្នាក់លេខ២លើពិភពលោក។ គោលនយោបាយ «ប្រទេសមួយប្រព័ន្ធពីរ» ក៏ទទួលបានភាពជោគជ័យយ៉ាងច្រើនអនេកក្នុងទឹកដីម៉ាកាវ។

សមិទ្ធផលនៃកិច្ចសហប្រតិបត្តិការ រវាងកម្ពុជា និងតំបន់រដ្ឋបាលពិសេសម៉ាកាវប្រទេសចិន មានច្រើនអនេកគួរឲ្យកត់សម្គាល់។ នាថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញមានជំនួបជាមួយ លោក Fernando Chui Sai On ប្រមុខដឹកនាំតំបន់រដ្ឋបាលពិសេសម៉ាកាវ ភាគីទាំង២បានពិភាក្សាគ្នាយ៉ាងស៊ីជម្រៅលើកិច្ចសហប្រតិបត្តិការវិស័យទេសចរណ៍ ពាណិជ្ជកម្ម និងវិស័យផ្សេងទៀត ដើម្បីជំរុញការអភិវឌ្ឍនៃទំនាក់ទំនងទ្វេភាគីនេះកាន់តែល្អប្រសើរ។

ឆ្លៀតក្នុងឱកាសនេះ សូមថ្លែងអំណរគុណដល់ម៉ាកាវដែលតែងចូលរួមលះបង់ដល់ការអភិវឌ្ឍក្នុងប្រទេសកម្ពុជា។

សូមជូនពរតំបន់រដ្ឋបាលពិសេសម៉ាកាវកាន់តែល្អប្រសើរនាថ្ងៃអនាគត!

សូមជូនពរមិត្តភាពកម្ពុជា និងចិន ស្ថិតស្ថេរជាអមតៈ!

# សារអបអរសាទរ របស់ឯកឧត្តម Wang Wentian

## ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា



ឯកឧត្តម Wang Wentian ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា

ពិព័រណ៍រូបភាពអបអរសាទរខួបអនុស្សាវរីយ៍២០ឆ្នាំ នៃការប្រគល់ម៉ាកាវមកប្រទេសចិនវិញ បានមកបង្ហាញជូនមិត្តភក្តិទាំងអស់ដែលមានវត្តមាននៅទីនេះ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមតំណាងឲ្យស្ថានទូតសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងអំណរគុណដល់មិត្តកម្ពុជាទាំងឡាយ ដែលតែងតែយកចិត្តទុកដាក់ និងគាំទ្រដល់ការអភិវឌ្ឍនៃតំបន់រដ្ឋបាលពិសេសម៉ាកាវប្រទេសចិន ក៏សូមអបអរសាទរយ៉ាងកក់ក្តៅជូនចំពោះខួបអនុស្សាវរីយ៍២០ឆ្នាំ នៃការប្រគល់ម៉ាកាវមកប្រទេសចិនវិញ។

នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ រដ្ឋាភិបាលចិនបានចាប់ផ្តើមអនុវត្តអធិបតេយ្យភាពសាជាថ្មីក្នុងទឹកដីម៉ាកាវ តំបន់រដ្ឋបាលពិសេស ម៉ាកាវ ត្រូវបានបង្កើតឡើងជាស្ថាពរ ហើយក៏បានឈានចូលដល់យុគសម័យថ្មីប្រវត្តិសាស្ត្ររបស់ស្វ័យគ្រប់គ្រងកម្រិតខ្ពស់នៃគោលនយោបាយ«ប្រទេសមួយ ប្រព័ន្ធពីរ» និងគោលនយោបាយ«ម៉ាកាវគ្រប់គ្រងដោយចិនម៉ាកាវ»។ ក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះគោលនយោបាយ«ប្រទេសមួយ ប្រព័ន្ធពីរ» និងច្បាប់មូលដ្ឋានគ្រឹះទទួលបានការអនុវត្តយ៉ាងគ្រប់ជ្រុងជ្រោយ កំណើនសេដ្ឋកិច្ចមានសន្ទុះកើនឡើង សង្គមមានស្ថិរភាព និងវិបុលភាព និងមានភាពរីកចម្រើនខ្លាំងលើគ្រប់វិស័យគួរឲ្យកត់សម្គាល់ នេះបានបង្ហាញពីភាពជោគជ័យក្នុងការអនុវត្តគោលនយោបាយ«ប្រទេសមួយ ប្រព័ន្ធពីរ»ដែលជាលក្ខណពិសេសនៃម៉ាកាវ ទៅកាន់ពិភពលោក។ ចក្ខុវិស័យនាថ្ងៃអនាគត តាមរយៈការបញ្ចូលយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិស៊ីជម្រៅ ម៉ាកាវនាថ្ងៃអនាគតនឹងរឹតតែត្រចះត្រចង់ និងលេចធ្លោ ហើយ«ផ្កាឈូកដ៏ស្រស់ផូរផង់»របស់ប្រទេសចិននឹងសាយក្លិនពិដោរដ៏ឈ្ងុយឈ្ងប់គ្រប់ទិសទី និងលាស់ស្លឹកខៀវខ្ចីបែកមែកសាខា។

ឆ្លៀតក្នុងឱកាសនៃខួបអនុស្សាវរីយ៍២០ឆ្នាំនៃការប្រគល់ម៉ាកាវមកប្រទេសចិនវិញ ស្ថានទូតចិនប្រចាំកម្ពុជាបានសហការជាមួយប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានសំខាន់ៗក្នុងប្រទេសកម្ពុជា ដើម្បីរួមគ្នាប្រារព្ធពិព័រណ៍រូបភាពនេះឡើង ក្នុងគោលបំណងបង្ហាញពីសមិទ្ធផល ដ៏ច្រើនអនេកដែលទទួលបានក្នុងជីវភាពរស់នៅ សេដ្ឋកិច្ចសង្គម និងកិច្ចទំនាក់ទំនងជាមួយក្រៅតំបន់ជាដើមរបស់តំបន់រដ្ឋបាលពិសេសម៉ាកាវ ដែលក្រោយពីបានប្រគល់មកប្រទេសចិនវិញ ជូនដល់មិត្តអ្នកអានក្នុងប្រទេសកម្ពុជាឲ្យបានជ្រាប ហើយក៏ជាយានមួយជួយដល់អ្នកទាំងអស់គ្នាក្នុងការស្វែងយល់អំពីម៉ាកាវ និងប្រទេសចិនថែមមួយកម្រិតទៀត ក៏សូមស្វាគមន៍ដល់អ្នកទាំងអស់គ្នាអញ្ជើញមកកម្សាន្តទេសចរណ៍ក្នុងតំបន់រដ្ឋបាលពិសេសម៉ាកាវ ដើម្បីយល់ដឹងអំពីការអនុវត្តប្រកបដោយភាពជោគជ័យនៃគោលនយោបាយ«ប្រទេសមួយ ប្រព័ន្ធពីរ»ក្នុងម៉ាកាវ ស្វែងយល់កាន់តែច្បាស់អំពីភាពទាក់ទាញនៃ«ដែនដីផ្កាឈូកដ៏អស្ចារ្យ»មួយនេះ។

សូមជូនពរតំបន់រដ្ឋបាលពិសេសម៉ាកាវរឹតតែត្រចះត្រចង់នាថ្ងៃអនាគត!

សូមជូនពរមិត្តភាពរវាងចិន និងកម្ពុជា ដែលប្រៀបដូចបងប្អូន ស្ថិតស្ថេរអមតៈយូរអង្វែង!

# លោកឧកញ៉ា Yum Sui Sang ប្រធានសមាគមអាណិកជន និងធុរកិច្ច ចិន ហុងកុង និងម៉ាកាវ នៅកម្ពុជា



លោក Yum Sui Sang ប្រធានសមាគមអាណិកជន និងធុរកិច្ច ចិន ហុងកុង និងម៉ាកាវ នៅកម្ពុជា។

ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍ ២០ឆ្នាំនៃការប្រគល់ម៉ាកាវមកប្រទេសចិនវិញ ខ្ញុំសូមតំណាងសមាគមអាណិកជន និងធុរកិច្ច ចិន ហុងកុង និងម៉ាកាវ នៅកម្ពុជា សូមសម្តែងគារវកិច្ចដោយស្មោះដល់ម៉ាកាវដ៏ស្រស់ស្អាតមួយនេះ សូមជូនពរម៉ាកាវមានភាពរឹតតែអស្ចារ្យ និងសូមជូនពរប្រទេសចិនមានភាពរីកចម្រើន និងវិបុលភាព។

ការប្រគល់ម៉ាកាវមកប្រទេសចិនគឺជាមហាសមិទ្ធផលដ៏អស្ចារ្យគ្រប់ជំនាន់ក្នុងប្រវត្តិសាស្ត្រនៃជនជាតិចិន ចាប់តាំងពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩មក ម៉ាកាវបានដើរលើវិថីមាគ៌ាដ៏ទូលាយមួយនៃការអភិវឌ្ឍរួម ជាមួយនឹងប្រទេសចិន។ នៅក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ គោលនយោបាយ «ប្រទេសមួយប្រព័ន្ធពីរ» ប្រព័ន្ធនយោបាយ«ម៉ាកាវគ្រប់គ្រងដោយជនជាតិចិនម៉ាកាវ» និងព្រមទាំងស្វ័យគ្រប់គ្រងកម្រិតខ្ពស់ សុទ្ធតែទទួលបានការអនុវត្តយ៉ាងគ្រប់ជ្រុងជ្រោយក្នុងម៉ាកាវ។ ស្ថិតនៅក្រោមការគាំទ្រពេញទំហឹងនៃរដ្ឋាភិបាលមជ្ឈិមបក្ស និងការខិតខំពីរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសម៉ាកាវ និងគ្រប់ជាន់ថ្នាក់នៃសង្គម បានធ្វើឲ្យម៉ាកាវទទួលបានសមិទ្ធផលនៃការអភិវឌ្ឍបានយ៉ាងច្រើនគួរឲ្យកត់សម្គាល់ ស្ថិរភាពក្នុងសង្គម វិបុលភាពនៃសេដ្ឋកិច្ច ការរស់នៅប្រកបដោយសុខដុមរមនា និងវប្បធម៌ចម្រុះ សុទ្ធសឹងតែទទួលបានការអភិវឌ្ឍបានយ៉ាងល្អប្រសើរ ដែលបានក្លាយទៅជាគំរូដ៏ជោគជ័យនៃការអនុវត្តគោលនយោបាយ«ប្រទេសមួយ ប្រព័ន្ធពីរ»។

ក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ ម៉ាកាវ និងប្រទេសចិនបានភ្ជាប់គ្នាយ៉ាងស្អិតល្មួត ស្ថិតនៅក្រោមការគាំទ្រពេញទំហឹងនៃរដ្ឋាភិបាលមជ្ឈិមបក្ស ធ្វើឲ្យជីវភាពរបស់ប្រជាជន សេដ្ឋកិច្ច និងវិស័យផ្សេងទៀតទទួលបានផ្លែផ្កា ជាទីគាប់ចិត្ត។ GDP នៃម៉ាកាវមានការកើនឡើងជិត៧.៥ដង ដែលកើន ពីជីវភាព៥១,៨៧២ពាន់លានប៉ាតាកាម៉ាកាវ (៦,៤៩១ពាន់លានដុល្លារសហរដ្ឋអាមេរិក) ក្នុងឆ្នាំ១៩៩៩ មក ៤៤០,៣១៦ពាន់លានប៉ាតាកាម៉ាកាវ (៥៤,៥៤៣ពាន់លានដុល្លារសហរដ្ឋអាមេរិក) ក្នុងឆ្នាំ២០១៨។ រីឯ GDP សម្រាប់មនុស្សម្នាក់ជាមធ្យមបានកើនពី១៥,២០០ដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៩ មក ៨២,៦០០ដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០១៨ ដែលតួលេខនេះបានធ្វើឲ្យម៉ាកាវជាប់ចំណាត់ថ្នាក់លេខ១ក្នុងអាស៊ី និងលេខ២នៅលើពិភពលោក។ បានក្លាយជាតំបន់«អ្នកមានបំផុត»ក្នុងចំណោមតំបន់ដទៃទៀតនៅលើពិភពលោក។ ទន្ទឹមនឹងនេះ ក៏បានជំរុញការអភិវឌ្ឍប្រកបដោយស្ថិរភាពនៃសុខុមាលភាពសេដ្ឋកិច្ច ហើយសមិទ្ធផលនៃការអភិវឌ្ឍទាំងនេះបានប្រើប្រាស់ក្នុងការបង្កើតអត្ថប្រយោជន៍ជូនដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ បានក្លាយជាគំនិតស្នូលនៃការអនុវត្តគោលនយោបាយ«ប្រទេសមួយ ប្រព័ន្ធពីរ» ដែលជាលក្ខណពិសេសនៃម៉ាកាវ។

ព័ត៌មានបន្ថែម អាននៅលើគេហទំព័រ
WWW.POSTKHMER.COM

# ខួបអនុស្សាវរីយ៍២០ឆ្នាំ នៃការប្រគល់ម៉ាកាវមកប្រទេសចិនវិញ



ថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៨៥ លោក Deng Xiaoping បានអញ្ជើញចូលរួមក្នុងជំនួបជាមួយលោក António dos Santos Ramalho Eanes អតីតប្រធានាធិបតីព័រទុយហ្កាល់ ដែលត្រូវបានអញ្ជើញមកបំពេញទស្សនកិច្ចក្នុងប្រទេសចិន។



ថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៩ លោក Jiang Zemin ប្រធានាធិបតីចិន អញ្ជើញចូលរួមក្នុងជំនួបជាមួយលោក Edmund Ho Hau Wah និងបានអបអរសាទរដល់លោកដែលត្រូវបានជាប់ឆ្នោត និងតែងតាំងជាប្រមុខដឹកនាំដំបូងគេនៃតំបន់រដ្ឋបាលពិសេសម៉ាកាវ។



ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ លោក Hu Jintao ប្រធានាធិបតីចិន អញ្ជើញចូលរួមក្នុងជំនួបជាមួយលោក Fernando Chui Sai On នៅ Zhongnanhai ប្រទេសចិន ដែលលោកត្រូវបានជាប់ឆ្នោត និងទទួលតំណែងជាប្រមុខដឹកនាំតំបន់រដ្ឋបាលពិសេសម៉ាកាវអាណត្តិទី៣។




ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៧ កិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការក្វាងទុង ហុងកុង ម៉ាកាវស៊ីជម្រៅ ជំរុញការកសាងគម្រោងផែនការក្នុងតំបន់ឆកសមុទ្រ ត្រូវបានចុះហត្ថលេខានៅទឹកដីហុងកុង ហើយលោកប្រធានាធិបតីចិន Xi Jinping បានអញ្ជើញជាអធិបតីក្នុងពិធីនេះ។



ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ លោកប្រធានាធិបតីចិន Xi Jinping អញ្ជើញចូលរួមក្នុងជំនួបជាមួយលោក Ho Iat Seng ដែលបានជាប់ឆ្នោត និងត្រូវបានតែងតាំងជាប្រមុខដឹកនាំតំបន់រដ្ឋបាលពិសេសម៉ាកាវអាណត្តិ ទី៥ដោយរដ្ឋាភិបាលមជ្ឈិមបក្ស។



ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ លោកប្រធានាធិបតីចិន Xi Jinping អញ្ជើញចូលរួមក្នុងជំនួបនៅ Zhongnanhai ជាមួយលោក Fernando Chui Sai On ប្រមុខដឹកនាំតំបន់រដ្ឋបាលពិសេសម៉ាកាវ ។



ជំនួបរវាងលោក Fernando Chui Sai On ប្រមុខដឹកនាំតំបន់រដ្ឋបាលពិសេសម៉ាកាវនិងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ខួបអនុស្សាវរីយ៍២០ឆ្នាំ នៃការប្រគល់ម៉ាកាវមកប្រទេសចិនវិញ
សហការឧបត្ថម្ភដោយ
THE CHINA HONG KONG & MACAU EXPATRIATE & BUSINESS ASSOCIATION OF CAMBODIA
健力集团 dynamic+ Improving Quality of Life, Shaping Better Tomorrows
sevensea SEAFOOD RESTAURANT by almondhospitality
ALLNISON Auditing and Consulting Co.,Ltd 凱旋會計事務所
REANDA Reanda LLKG (Cambodia) Co., Ltd





# ខួបអនុស្សាវរីយ៍២០ឆ្នាំ នៃការប្រគល់ម៉ាកាវមកប្រទេសចិនវិញ



ទិដ្ឋភាពម៉ាកាវពីលើអាកាស



ការរីកស្គុសស្គាយនៃផ្កាឈូកដែលមាននៅលើទីលាននោះជាអំណោយរបស់រដ្ឋាភិបាលប្រជាជនមជ្ឈិមបក្សជូនចំពោះតំបន់រដ្ឋបាលពិសេសម៉ាកាវក្នុងឆ្នាំ១៩៩៩ ។



ព្រឹត្តិការណ៍ម៉ារ៉ាតុងអន្តរជាតិម៉ាកាវ គឺជាការប្រកួតដែលត្រូវបានទទួលស្គាល់ដោយសមាគមម៉ារ៉ាតុងអន្តរជាតិ និងការរត់លើដងផ្លូវ (AMIS)។



នៅឆ្នាំ២០០៧ ម៉ាកាវបានក្លាយជាតំបន់មួយក្នុងចំណោមតំបន់មួយចំនួននៅក្នុងពិភពលោក ដែលបានផ្តល់ការអប់រំជាកាតព្វកិច្ចរយៈពេល១៥ឆ្នាំ។



ចាប់តាំងពីការវិលត្រឡប់ទៅកាន់ប្រទេសចិនរយៈពេល២០ឆ្នាំនេះ ជីវភាពប្រជាពលរដ្ឋក្នុងតំបន់រដ្ឋបាលពិសេសម៉ាកាវមានសុខដុមរមនា។ តំបន់រដ្ឋបាលម៉ាកាវបានចំណាយ ទៅលើសេវាកម្មសង្គមកិច្ចជាច្រើន និងប្រាក់អត្ថប្រយោជន៍ផ្សេងទៀត។



ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៥ តំបន់ទីក្រុងប្រវត្តិសាស្ត្រម៉ាកាវ ត្រូវបានចាត់ជាសំណង់តែ១គត់នៅក្នុងឆ្នាំនោះ ក្នុងការស្នើដាក់ចូលជាសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោក ដោយប្រទេសចិន។ ក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្បត្តិបេតិកភណ្ឌពិភពលោកលើកទី ២៩ បានសម្រេចដាក់បញ្ចូលតំបន់ទីក្រុងប្រវត្តិសាស្ត្រម៉ាកាវនេះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

រូបថត COURTESY OF CHINESE EMBASSY


THE CHINA HONG KONG & MACAU EXPATRIATE & BUSINESS ASSOCIATION OF CAMBODIA

## លោកឧកញ៉ា YUM SUI SANG និងសមាជិកក្រុមប្រឹក្សាភិបាល

| | | | | |
|---|---|---|---|---|
| លោកស្រី **Wong Swie Hwa** | លោក **So Man Kit** | លោក **Tom Kimson** | លោក **Luu Meng** | លោក **Mo Shun Kan** |
| លោក **Jacky S.Choi** | លោក **Ng Shuen Fai** | លោក **Paul Zheng** | លោក **Liu Sheng Qiu** | លោក **Ju Lius Ling** |
| លោក **Lin Zhi Qiang** | លោក **Li Xu Dong** | លោក **Raymond Tam** | លោក **Johnny Mo** | លោក **Yeung Chi Ching** |
| លោក **Li Song** | លោក **Chan Huy Luong** | លោកស្រី **Hazel Zhao (Haiming)** | លោក **Tang Xue Jun** | លោក **Pan Gan Wu** |